**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៥៩
ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១
ជំនុំជម្រះលេខ ២១៣
ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២១
**សាលក្រមព្រហ្មទណ្ឌ**
លេខ ៥៨ ខ.១/៧០៣
ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការសួរដេញដោលក្នុងសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៨ និង ៣០នាទីព្រឹក ដោយមានសមាសភាពៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៩ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ដែលមាន

**ជនជាប់ចោទ ៖**

១. គោត្តនាម និងនាម [redacted] **យុឈាន** ហៅ ប៉ាង ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលជាប់ឃុំ នៅភូមិ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី១០ថ្មី មុខរបរសិស្ស នៅលីវ ឪពុកឈ្មោះ[redacted]ឈីង(រ) ម្តាយឈ្មោះ [redacted]គីមរួន(រ) ប្រវត្តិផ្តន្ទាទោសៈ គ្មាន។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់លេខ ៦០ ឃខ/ស ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១។

២-គោត្តនាម និងនាម [redacted] **សុត័ណ្ណា** ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលជាប់ឃុំ នៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០៥ថ្មី មុខរបររៀនកាត់សក់ នៅលីវ ឪពុកឈ្មោះ[redacted]សុភ័ក្រ(រ) ម្តាយឈ្មោះ[redacted]ស៊ីវ៉ែន(រ) ប្រវត្តិនៃការផ្តន្ទាទោសៈ គ្មាន។(ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់លេខ ៥៩ ឃខ/ស ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១។

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅតាមបណ្តោយផ្លូវ៦០ម៉ែត្រ ស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-**មេធាវីការពារសិទ្ធិជនជាប់ចោទ**៖លោក [redacted]
មានអាសយដ្ឋាននៅការិយាល័យនាគព័ន្ធ ផ្ទះលេខ៥៥ ភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

**ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] **លីសាន់** ភេទស្រី អាយុ ១៩ឆ្នាំ រស់នៅភូមិខ្នារចាស់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

-បានឃើញ ដីកាសម្រេចចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៤២៧ ពស.ព្រជ/ក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## **<u>អង្គហេតុដែលចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះ</u>**

យោងតាមអង្គហេតុដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ ២០២១ វេលាម៉ោង១៩និង៣០នាទី នៅបណ្តោយផ្លូវ៦០ម៉ែត្រ ស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ជនជាប់ចោទឈ្មោះ [redacted] យូឈាន និងឈ្មោះ [redacted] សុភ័ណ្ឌ បានជិះម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៦ ពាក់ស្លាកលេខ ភ្នំពេញ1AP8636 បានធ្វើសកម្មភាពលួចយកទូរស័ព្ទដៃមួយគ្រឿងម៉ាកIPhone 7Pluse ពណ៌ផ្កាឈូក ពីជនរងគ្រោះឈ្មោះ [redacted] លីសាន់ ភេទស្រី អាយុ១៩ឆ្នាំ។ រហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ទើបកម្លាំងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនជនសង្ស័យទាំងពីរនាក់ខាងលើមានឈ្មោះ [redacted] យូឈាន និងឈ្មោះ [redacted] សុភ័ណ្ឌ បានតែម្តង។

-បានឃើញ សាលក្រមលេខ ០១ (ខ.១)/១២ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២១ ដែលសម្រេចបង្វិលសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរពីបទលួចមានស្ថានទម្ងន់ទោស។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥១៣ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣២៣៨ ពស.ព្រសស/ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

## **<u>នាពេលសវនាការ</u>**

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] យូឈាន ភេទប្រុស

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីសាន់ ភេទស្រី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ។

-ក្រោយពីបានពិនិត្យកស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ។

## **<u>សំអាងហេតុ</u>**

១-ជនជាប់ចោទឈ្មោះ [redacted] យូឈាន និងឈ្មោះ [redacted] សុភ័ណ្ឌ ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវ៦០ម៉ែត្រ ភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែង

ឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង ៣៥៧ នៃក្រមព្រហ្មទណ្ឌ តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣២៣៨ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

២. តាមលទ្ធផលនៃការសួរដេញដោលក្នុងសវនាការ និងពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា ពិតជាមានអង្គហេតុលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិដោយជនជាប់ចោទខាងលើប្រាកដមែន។

៣. ភស្តុតាងដាក់បន្ទុករួមមាន ៖

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យូឈាន បានឆ្លើយថា៖ ខ្លួនទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយ នៅដំណាក់មន្ត្រីនគរបាលយុត្តិធម៌និងនៅដំណាក់កាលតំណាងអយ្យការទុកជាបានការដដែល។ ខ្លួនសារភាពថា ពិតជាបានលួចទូរស័ព្ទម៉ាកអាយហ្វូន ពីជនរងគ្រោះពិតមែន។ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០៧ល្ងាច ខ្លួនជាមួយឈ្មោះ [redacted] សុភ័ណ្ឌ បានជិះម៉ូតូម៉ាកហុងដាឌ្រីមស៊េរីឆ្នាំ២០១៦ ពណ៌ខ្មៅ ជារបស់ឈ្មោះ យឹម ចេញពីកន្លែងលក់ទឹកត្នោតជូរនៅមុខផ្សារកុងតឺណឺរសំដៅទៅរង្វង់មូលផ្លូវ៦០ម៉ែត្រ កាច់ទៅស្តាំដៃ ពេលដល់មុខតារាងបាល់យុវជន បានឃើញមនុស្សស្រីជិះម៉ូតូម្នាក់ឯងលេងទូរស័ព្ទបណ្តើរជិះបណ្តើរ បន្ទាប់មកខ្លួនបានឆក់ ទូរស័ព្ទជនរងគ្រោះបានសម្រេច រួចបើកទៅកន្លែងផឹកទឹកត្នោតជូរវិញ។ បន្ទាប់មកដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០២១ សមត្ថកិច្ចបានចាប់ឃាត់ខ្លួននៅដំដែកជាមួយឈ្មោះ [redacted] សុភ័ណ្ឌ។ ខ្លួនទើបតែលួចគេជាលើកដំបូងក៏ត្រូវសមត្ថកិច្ច ចាប់ខ្លួនតែម្តង។ នៅថ្ងៃកើតហេតុខ្លួនលួចទូរស័ព្ទជនរងគ្រោះ ជាមួយឈ្មោះ [redacted] សុភ័ណ្ឌ តែប៉ុណ្ណោះ ចំពោះអ្នកផ្សេងទៀតនៅមុខផ្សារកុងតឺណឺ តែពួកគាត់មិនដឹងថាខ្លួនលួចគេនោះទេ។ ចំពោះទូរស័ព្ទដែលខ្លួនលួចបានប្រគល់ទៅ អោយម្ចាស់គេវិញហើយ។ ពេលសមត្ថកិច្ចឃាត់ខ្លួន សមត្ថកិច្ចពុំបានដកហូតអ្វីទេ។ នៅកន្លែងផឹកទឹកត្នោតជូរខ្លួននៅជាមួយឈ្មោះ ហុង សុភ័ណ្ឌ ឈ្មោះ យឹម ភេទប្រុស ឈ្មោះ ញ៉ា ភេទប្រុស អាយុប្រហែល១៨ឆ្នាំ ឈ្មោះ រចនា ភេទ ប្រុស អាយុប្រហែល១៩ឆ្នាំ។ ខ្លួនសុំតុលាការបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ និងដោយសារខ្លួនកំពុងនៅសិក្សាផងដែរ ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភ័ណ្ឌ បានឆ្លើយថា៖ ខ្លួនទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយ នៅដំណាក់មន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលតំណាងអយ្យការទុកជាបានការដដែល។ ខ្លួនសារភាពថា ពិតជាបានលួចទូរស័ព្ទម៉ាកអាយហ្វូន ពីជនរងគ្រោះពិតមែន។ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០៧ល្ងាច ខ្លួនជាមួយឈ្មោះ ឈាន ទៅទិញស្រាដោយជិះម៉ូតូម៉ាកហុងដាឌ្រីមស៊េរីឆ្នាំ២០១៦ ពណ៌ខ្មៅ ជារបស់ឈ្មោះ យឹម ចេញពីកន្លែងលក់ទឹកត្នោតជូរ។ ពេលហួសរង្វង់មូលផ្លូវ៦០ម៉ែត្របន្តិច ក៏បានឃើញមនុស្សស្រីជិះម៉ូតូម្នាក់ឯង លេងទូរស័ព្ទបណ្តើរ ជិះបណ្តើរ បន្ទាប់មកឈ្មោះ ឈាន បានឆក់ទូរស័ព្ទជនរងគ្រោះបានសម្រេចដោយពេលនោះខ្លួនជាអ្នកបើកម៉ូតូ រួចបើកទៅកន្លែងផឹកទឹកត្នោតជូរវិញ។ បន្ទាប់មកដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ សមត្ថកិច្ចបានចាប់ឃាត់ខ្លួន នៅដំដែកជាមួយឈ្មោះ ឈាន។ ខ្លួនទើបតែលួចគេជាលើកដំបូងក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ នៅថ្ងៃកើតហេតុខ្លួនលួចទូរសព្ទជនរងគ្រោះជាមួយឈ្មោះ ឈាន តែប៉ុណ្ណោះ ចំពោះអ្នកផ្សេងទៀតនៅមុខផ្សារកុងតឺន័រ តែពួកគាត់មិនដឹងថាខ្លួនលួចគេនោះទេ។ ពេលសមត្ថកិច្ច

ឃាត់ខ្លួនសមត្ថកិច្ចបានដកហូតម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០១៦ ពណ៌ខ្មៅ របស់ឈ្មោះ ឃឹម ទូរស័ព្ទម៉ាក អាហ្វូនស៊ិចផ្លាស និងម៉ាកអាយហ្វូន សីរវែនផ្លាសចំនួន០១គ្រឿង។ នៅកន្លែងផឹកទឹកត្នោតជូរខ្លួននៅជាមួយឈ្មោះ ឈាន ឈ្មោះ ឃឹម ភេទប្រុស និងពីរនាក់ទៀតមិនស្គាល់ឈ្មោះ។ ខ្លួនសុំតុលាការបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ ។

-ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីសាន់ ភេទស្រី បានឆ្លើយថា៖ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ វេលាម៉ោង៧យប់ ខ្លួនបានជិះម៉ូតូចេញពីផ្លូវ៦០ម៉ែត្រដើម្បីទៅផ្ទះ ពេលជិះជិតដល់ភ្លើងស្តុបផ្លូវ៦០ម៉ែត្រ មានគេទូរស័ព្ទខលចូលទូរស័ព្ទរបស់ខ្លួន ពេលនោះខ្លួនដកទូរស័ព្ទពីកាបូប ប្រុងនិយាយ ស្រាប់តែមានម៉ូតូ១គ្រឿងជិះគ្នា២នាក់(ប្រុស) បានឆក់ទូរស័ព្ទរបស់ខ្លួន បន្ទាប់មកខ្លួនស្រែកថាចោរឆក់ទូរស័ព្ទ ពេលនោះវាដោះមួកការពារគប់ខ្លួន។ ក្រោយមកជនល្មើសទាំងពីរនាក់នោះបានបង្អង់ម៉ូតូអោយស្មើខ្លួនរួចគៀរខ្លួន បណ្តាលអោយរេចង្កូតម៉ូតូប៉ះអ្នកដទៃបណ្តាលអោយដួលទាំងអស់គ្នា ធ្វើអោយខ្លួនរបួសត្របកភ្នែកដេរអស់១១ថ្នេរ និងរបួសម៉ាត់ដេរអស់៦ថ្នេរ ទាំងលើទាំងក្រោមបាក់ធ្មេញចំនួន១ និងស្រាលលាក្បាលខាងឆ្វេង។ ចំណែកអ្នកដួលម៉ូតូម្ខាងទៀតរងរបួសចំនួន៤នាក់។ ក្រោយមកទៀតជនល្មើសក៏បើកម៉ូតូរត់បាត់ទៅ ហើយខ្លួនក៏ដាក់ពាក្យបណ្តឹងទៅនគរបាលប៉ុស្តិ៍សង្កាត់ស្លក្រាមដើម្បីស្វែងរកចាប់ជនល្មើស។ ខ្លួនចំណាំមុខជនល្មើសចំនួន២នាក់ ច្បាស់ពេលពួកវាទៅដោះលេខកូដទូរស័ព្ទ។ ខ្លួនចំណាយលើថ្លៃព្យាបាលរបួសដែលបណ្តាលមកពីជនល្មើសគៀរម៉ូតូអស់ចំនួនបីលានរៀល ខ្លួនចំណាយទៅលើការសងទៅជនរងគ្រោះដែលបណ្តាលមកពីជនល្មើសគៀរខ្លួនអោយទៅបុកគេ អស់ចំនួន១,៣០០ដុល្លារអាមេរិក ថ្លៃជួសជុលម៉ូតូដែលខូច ដែលដួលបណ្តាលមកពីជនល្មើសគៀរអស់ចំនួន៥០០ដុល្លារអាមេរិក តម្លៃទូរស័ព្ទ៥៦០ដុល្លារ។ ខ្លួនទាមទារការខូចខាត និងជម្ងឺចិត្តពីជនជាប់ចោទទាំងពីរនាក់ចំនួន ៥០០០ដុល្លារអាមេរិក។

៥-តាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងព្រមទាំងពិនិត្យភស្តុតាងដែលសមត្ថកិច្ចបានដកហូត មានភាពស៊ីសង្វាក់គ្នានឹងកំណត់ហេតុរបស់នគរបាលយុត្តិធម៌ ដែលអាចបញ្ជាក់បានថា៖ កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២១ ពិតជាមានករណីលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តិដោយជនជាប់ចោទ ប្រាកដមែន។

៦-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] យូឈាន និងឈ្មោះ [redacted] សុភ័ណ្ឌ មានធាតុផ្សំគ្រប់គ្រាន់នៃបទល្មើសលួច បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូចការចោទប្រកាន់របស់តំណាងអយ្យការ។

៨-មានភស្តុតាងគ្រប់គ្រាន់កំណត់ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] យូឈាន និងឈ្មោះ [redacted] សុភ័ណ្ឌ ពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅតាមបណ្តោយផ្លូវ៦០ម៉ែត្រ ស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៩-ការប្រកាសទោស៖ គប្បីប្រកាសទោសដាក់ពន្ធនាគារដល់ជនជាប់ចោទឈ្មោះ [redacted] សុភ័ណ្ឌ ក្នុងកម្រិតអប្បបរមានៃទោស និងគប្បីប្រកាសទោសដាក់ពន្ធនាគារក្រោមកម្រិតអប្បបរមានៃ

ទោស ព្រមទាំងឱ្យមានការព្យួរនូវការអនុវត្តទោសមួយផ្នែកដល់ជនជាប់ចោទឈ្មោះ [redacted] យូឈាន ដោយពិនិត្យឃើញនូវលក្ខខណ្ឌមួយចំនួនដែលពាក់ព័ន្ធដូចខាងក្រោម៖

-ជនជាប់ចោទឈ្មោះ [redacted] យូឈាន ជាអនីតិជន យោងតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ទោសអនុវត្តចំពោះអនីតិជនត្រូវបន្ថយពាក់កណ្ដាល។

-ព្យសនកម្ម (ការខូចខាត) ដែលកើតពីអំពើល្មើសមានលក្ខណៈតិចតួច។

-ជនជាប់ចោទទើបប្រព្រឹត្តអំពើល្មើសជាលើកទី១។

១០-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានថា រក្សាការចោទប្រកាន់លើជនជាប់ចោទ តាមដីកាសន្និដ្ឋានស្ថាពរ និងប្តឹងសុំទៅក្រុមជំនុំជម្រះសម្រេចផ្តន្ទាទោសជនល្មើសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការពិចារណា។

១១-វត្ថុតាងមាន៖ ម៉ូតូម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ផលិតឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ1AP-8636 ០១គ្រឿង និងទូរស័ព្ទដៃម៉ាក Iphone6Plus ពណ៌ទឹកប្រាក់ ដកហូតពីជនជាប់ចោទជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។ ចំពោះទូរស័ព្ទដៃម៉ាក Iphone7Plus ពណ៌ផ្កាឈូក ជារបស់ដើមបណ្តឹងរដ្ឋប្បវេណី គប្បីតុលាការប្រគល់ឲ្យសាមីខ្លួនវិញ។

១១. ជនរងគ្រោះឈ្មោះ [redacted] លីសាន់ ភេទស្រី បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងការខូចខាត និងជម្ងឺចិត្តពីជនជាប់ចោទទាំងពីរនាក់ចំនួន ៥០០០ ដុល្លារអាមេរិក គប្បីតុលាការពិនិត្យពិចារណា និងសម្រេចតាមការខូចខាតជាក់ស្តែង ដោយឆន្ទានុសិទ្ធិ។

**<u>វិនិច្ឆ័យសេចក្តី</u>**

**១. ផ្តន្ទាទោស**

**ក.** ឈ្មោះ [redacted] យូឈាន ហៅ ប៉ាង ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលជាប់ឃុំ នៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី១០ថ្មី មុខរបរសិស្ស នៅលីវ ឪពុកឈ្មោះ [redacted] ឈីង(រ) ម្តាយឈ្មោះ [redacted] គីមសួន(រ) ប្រវត្តិផ្តន្ទាទោស៖ គ្មាន។ (ក្នុងឃុំ)

**ដាក់ពន្ធនាគារ កំណត់ ១៨ (ដប់ប្រាំបី) ខែ។ តែទោសនេះត្រូវអនុវត្តដូចខាងក្រោម៖**

-ទោសអនុវត្តក្នុងពន្ធនាគាររយៈពេល ០១(មួយ)ឆ្នាំ

-ទោសនៅសល់ត្រូវព្យួរការអនុវត្តធម្មតាស្របតាមមាត្រា១០៤ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

**ពីបទ៖** លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅតាមបណ្តោយផ្លូវ៦០ម៉ែត្រ ស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**ខ.** ឈ្មោះ [redacted] សុក័ណ្ណ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលជាប់ឃុំ នៅភូមិត្រពាំងសេះ សង្កាត់

គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី ០៥ថ្មី មុខរបររៀនកាត់សក់ នៅលីវ ឪពុកឈ្មោះ [redacted] សុភ័ក្រ(រ) ម្តាយឈ្មោះ [redacted] ស៊ីវ៉ែន(រ) ប្រវត្តិនៃការផ្តន្ទាទោស៖ គ្មាន។ (ក្នុងឃុំ)

**ដាក់ពន្ធនាគារ កំណត់ ០៣ (បី)ឆ្នាំ។**

**ពីបទ៖** លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅតាមបណ្តោយផ្លូវ៦០ម៉ែត្រ ស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. ឲ្យឈ្មោះ [redacted] យុឈាន ព្រមទាំងអាណាព្យាបាល និងឈ្មោះ [redacted] សុភ័ណ្ឌ រួមគ្នាសង ការខូចខាត និងជម្ងឺចិត្តឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីសាន់ ភេទស្រី ចំនួន ១០ ០០០ ០០០ (ដប់លាន) រៀល។ ការទាមទារលើសពីនេះ បដិសេធចោល។

៣. វត្ថុតាងមាន៖

-ម៉ូតូម៉ាក ហុងដាឌ្រីម C125 ស៊េរីឆ្នាំ២០១៦ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AP-8636 លេខតួ-លេខម៉ាស៊ីន ៩៦៥២៧០២ (មានកញ្ចក់ កាបន្ទះពណ៌ខ្មៅ មានកូនសោរ) ចំនួន ០១ គ្រឿង និងទូរស័ព្ទដៃម៉ាក IPHONE 6PLUS Model: A1522 ពណ៌ទឹកប្រាក់ ចំនួន ០១ គ្រឿង សម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

-ទូរស័ព្ទដៃម៉ាក IPHONE 7PLUS Model: A1661 ពណ៌ផ្កាឈូក ចំនួន ០១គ្រឿង សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ ស្របតាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះបញ្ចប់ការសួរដេញដោលនៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ពស.២៥៦៥

សៀមរាប, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner